ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ខេត្តបន្ទាយមានជ័យ

ស្រុកមង្គលបុរី

រដ្ឋបាលឃុំបន្ទាយនាង

លេខ.....០២៣...../២១ ដ.ក

ដីកា

ស្តីពី

ការទប់ស្កាត់ការបោះសំរាមចោលនៅតាមដងផ្លូវ ឬទីសាធារណៈនៃទីប្រជុំជន

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែ មីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់។
- បានឃើញអនុក្រឹត្យលេខ ២២ អនក្រ.បក ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០០២ របស់រាជរដ្ឋាភិបាលកម្ពុជាស្តីពីការធ្វើវិមជ្ឈការអំណាច តួនាទី និងភារៈកិច្ចទៅអោយក្រុមប្រឹក្សាឃុំ សង្កាត់ ។
- បានឃើញអនុក្រឹត្យលេខ ១១៣ អនក្រ.បក ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៥ របស់រាជរដ្ឋាភិបាលកម្ពុជាស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន។
- យោងលទ្ធផលសិក្ខាសាលាពីគ្រោះយោបល់ជាមួយប្រជាពលរដ្ឋលើសេចក្តីព្រាងដីកាឃុំស្តីពី ការទប់ស្កាត់ការបោះសំរាមចោលនៅតាមដងផ្លូវ ឬ ទីសាធារណៈ នៅឃុំបន្ទាយនាង កាលពីថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២១ ។
- យោងស្មារតីអង្គប្រជុំសាមញ្ញលើកទី៥៤ អាណត្តិទី៤របស់ក្រុមប្រឹក្សាឃុំបន្ទាយនាងនាថ្ងៃទី.២៤ ខែធ្នូ ឆ្នាំ២០២១

ដោយមើលឃើញពីការបោះចោលសំរាមបែបអនាធិបតេយ្យនៅតាមដងផ្លូវ ឬ ទីសាធារណៈនៃទីប្រជុំជន របស់ ប្រជាពលរដ្ឋ **ក្រុមប្រឹក្សាឃុំបន្ទាយនាង។**

សម្រេច

ប្រការ១.ដីកានេះមានគោលបំណង ដើម្បីពង្រឹងការគ្រប់គ្រងសំរាមឱ្យកាន់តែមានប្រសិទ្ធភាព និងលើកកម្ពស់ការ យល់ដឹងរបស់ប្រជាពលរដ្ឋក្នុងការទេកុដាក់សំរាមឱ្យបានត្រឹមត្រូវ និងសេវាប្រមូលសំរាម។

ប្រការ២. ដីកានេះមានវិសាលភាពអនុវត្តតែនៅក្នុងដែនដី នៃឃុំបន្ទាយនាង។

ប្រការ៣.រដ្ឋបាលឃុំបន្ទាយនាងផ្តល់ឱកាស និងលើកទឹកចិត្តឱ្យក្រុមយុវជនចូលរួមនៅក្នុងកិច្ចប្រជុំប្រចាំខែរបស់ក្រុមប្រឹក្សាឃុំឱ្យបានទូលំទូលាយ។

ប្រការ៤.រដ្ឋបាលឃុំបន្ទាយនាងថែរក្សាបរិស្ថាន និងរៀបចំសណ្តាប់ធ្នាប់សាធារណៈអោយបានល្អ ដើម្បីបង្កលក្ខណៈងាយស្រួលដល់ការរស់នៅរបស់ប្រជាពលរដ្ឋប្រកបដោយផាសុខភាព។

ប្រការ៥.ក្រុមប្រឹក្សាឃុំ ប៉ុស្តិ៍នគរបាលរដ្ឋបាល មេភូមិគ្រប់ភូមិ បណ្តាញយុវជន សហគមន៍ នាយកសាលា និង មណ្ឌលសុខភាព ត្រូវបង្កើតការអប់រំផ្សព្វផ្សាយពីសិទ្ធមនុស្ស ប្រជាធិបតេយ្យ អភិបាលលិច្ចល្អ និងផលប៉ះពាល់នៃការបោះសំរាម

ចោលនៅតាមដងផ្លូវ ឬទីសាធារណៈនៃ ទីប្រជុំជន ទៅដល់ប្រជាពលរដ្ឋ ម្ចាស់សណ្ឋាគារ ម្ចាស់ផ្ទះសំណាក់ ម្ចាស់គោជនីយដ្ឋាន នៅក្នុងឃុំបន្ទាយនាងឱ្យបានទូលំទូលាយ ។

ប្រការ៦.បញ្ចូលផែនការផ្សព្វផ្សាយពីផលប៉ះពាល់នៃការបោះសំរាមចោលនៅតាមដងផ្លូវ ឬទីសាធារណៈនៃទីប្រជុំជន ទៅក្នុងកម្មវិធីវិនិយោគ ៣ឆ្នាំរំកិលរបស់ឃុំ និងផែនការអភិវឌ្ឍន៍ឃុំ។

ប្រការ៧.ហាមជនគ្រប់រូបបោះចោល ឬដុតសំរាម សំណល់រឹងទីប្រជុំជន នៅតាមដងផ្លូវ ទីសាធារណៈ ទីវាល តាមប្រព័ន្ធទឹកលូ ឬប្រភពទឹកសាធារណៈ ឬក្នុងដីកម្មសិទ្ធិឯកជន។

ប្រការ៨.ម្ចាស់សំរាម សំណល់រឹងទីប្រជុំជនត្រូវរក្សាទុកនូវកញ្ចប់ ឬ ធុងផ្ទុកសំរាមសំណល់រឹងរបស់ខ្លួននៅ ក្នុងរបង ឬបរិវេណនៃលំនៅឋាន អគារ ឬ ទីតាំងរបស់ខ្លួន និងត្រូវបញ្ជេញទៅតាមពេលម៉ោងដែលកំណត់ដោយរដ្ឋបាលឃុំ។

ប្រការ៩.ជនទាំងឡាយណាដែលបានប្រព្រឹត្តល្មើសដូចមានចែងនៅក្នុងប្រការ៧ និងប្រការ៨នៃដីកានេះ នឹងត្រូវធ្វើ ការណែនាំ លើកទី១ដោយផ្ទាល់មាត់ លើកទី២ និងលើកទី៣ ជាលាយលក្ខណ៍អក្សរ។ ក្នុងករណី ជនដែលបាន ប្រព្រឹត្តល្មើសនៅតែមិនស្តាប់តាមការអប់រំណែនាំរបស់អាជ្ញាធរឃុំ នឹងត្រូវទទួលពិន័យជាប្រាក់ដូចខាងក្រោម៖

- ចំនួន ២០.០០០ (ពីរម៉ឺនរៀល) សម្រាប់លំនៅដ្ឋាន។
- ចំនួន ១៥០.០០០ (មួយសែនប្រាំម៉ឺនរៀល) សម្រាប់ទីតាំងអាជីវកម្ម ទីតាំងសេវាកម្ម និង ទីតាំងសិប្បកម្ម។
- ចំនួន ៤០០.០០០ (បួនសែនរៀល) សម្រាប់រោងចក្រ សហគ្រាស ក្រុមហ៊ុន ។

ក្នុងករណីមិនរាងចាល ត្រូវទទួលការពិន័យជាប្រាក់ទ្វេដងនៃប្រាក់ពិន័យកាលពីលើកមុន។

ប្រការ១០. ថវិកាដែលទទួលបានពីការផាកពិន័យ ត្រូវដាក់បញ្ចូលជាថវិកាមូលនិធិសម្រាប់អភិវឌ្ឍន៍ឃុំ និងវគ្គផ្សព្វ ផ្សាយដល់ប្រជាពលរដ្ឋឱ្យយល់ដឹងពីការគ្រប់គ្រងសំរាម សំណល់រឹងប្រកបដោយប្រសិទ្ធភាព។

ប្រការ១១. រដ្ឋបាលឃុំ ត្រូវបង្កើតគណៈកម្មការ និងជនបង្គោលស្ម័គ្រចិត្តតាមភូមិសម្រាប់ជួយផ្សព្វផ្សាយ និងតាមដានពីប្រសិទ្ធភាពនៃការអនុវត្តដីកាឃុំបន្ទាប់ពីបានអនុម័ត។

ប្រការ១២. អាជ្ញាធរមូលដ្ឋាន (មេឃុំ ក្រុមប្រឹក្សាឃុំ មេភូមិ ប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ) បណ្តាញយុវជន សហគមន៍ នាយកសាលា និង មណ្ឌលសុខភាព ត្រូវធ្វើការផ្សព្វផ្សាយដីកានេះ ជូនដល់ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធនៅក្នុងមូលដ្ឋានឱ្យបានទូលំទូលាយ។

ប្រការ១៣.ដីកានេះ មានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ថ្ងៃសុក្រ ៥រោច ខែមិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥
បន្ទាយនាង ថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០២១

មេឃុំ

ថា ឌី

ចំលងជូន

- រដ្ឋបាលស្រុកមង្គលបូរី
- ការិយាល័យសង្គមកិច្ច និងសុខុមាលភាពសង្គមស្រុកមង្គលបូរី "ដើម្បីគោរពជូនជ្រាប"
- មេភូមិគ្រប់ភូមិ "ដើម្បីសហការអនុវត្តន៍"
- ឯកសារ-កាលប្បវត្តិ